ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

នីតិរដ្ឋ ភាតរភាព វឌ្ឍនភាព

# បទបញ្ជាផ្ទៃក្នុង

របស់

# គណបក្សប្រជាធិបតេយ្យជឿនលឿន

Internal Regulation

DEMOCRATIC PROGRESSIVE PARTY

# ជំពូកទី១
# សមាជិកភាព

**ប្រការ ១ ៖**

សមាជិកគណបក្សត្រូវបំពេញកាតព្វកិច្ច គោរព និងអនុវត្ត ច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង បទប្បញ្ញត្តិ និង សេចក្តីសម្រេចនានារបស់គណបក្ស។

រាល់ការបញ្ចេញមតិ ឬធ្វើសកម្មភាព មិនជាផ្លូវការរបស់គណបក្ស គឺជាការទទួលខុសត្រូវរបស់សាមីខ្លួន។

ក្នុងករណីដែលសមាជិកគណបក្ស ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ បានប្រព្រឹត្តល្មើសដូចមានចែងខាងលើ ធ្វើឱ្យ ប៉ះពាល់ផលប្រយោជន៍គណបក្ស ដោយប្រការណាមួយជាយថាហេតុ គណៈកម្មាធិការវិន័យ មានសិទ្ធិពេញលេញក្នុង ការសម្រេច កោះមកបំភ្លឺ ដាក់ពិន័យ ឬការបញ្ចប់សមាជិកភាព លុបឈ្មោះចេញពីបញ្ជីគណបក្ស បន្ទាប់ពីគណៈកម្មាធិ ការអចិន្ត្រៃយ៍គណបក្សអនុម័តយល់ព្រមលើសេចក្តីសម្រេចនោះ។

ការគោរពច្បាប់ ក្រមសីលធម៌ វិន័យ និងលក្ខន្តិកៈ-បទបញ្ជាផ្ទៃក្នុង-បទប្បញ្ញត្តិ-សេចក្តីសម្រេច របស់គណបក្ស គឺជាលក្ខណៈសម្បត្តិមួយដ៏សំខាន់ សម្រាប់ធ្វើការវាយតម្លៃក្នុងការជ្រើសរើសចូលជាថ្នាក់ដឹកនាំគណបក្ស និងជាមាជិក គណៈកម្មាធិការនាយក គណៈកម្មាធិការវិន័យ និងគណៈកម្មាធិការប្រតិបត្តិ របស់គណបក្ស។

**ប្រការ ២ ៖**

ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ អាចប្រកាសគាំទ្រគណបក្សប្រជាធិបតេយ្យ ជឿនលឿនបានដោយសេរី។ ការចូលជាសមាជិកសកម្មរបស់គណបក្ស ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដែល មានឯកសារភ្ជាប់មកជាមួយតាមតម្រូវការ អាចមានបិទភ្ជាប់រូបថត និងអត្តសញ្ញាណប័ណ្ណថតចម្លង ដើម្បីចុះបញ្ជីក្នុង ឯកសារផ្លូវការណាមួយរបស់គណបក្ស។

**ប្រការ ៣ ៖**

សមាជិកគណបក្ស មានសិទ្ធិចូលរួមផ្តល់មតិយោបល់ និងមធ្យោបាយដល់គណបក្ស។ តាមការកោះហៅមក ចូលរួមប្រជុំ សមាជិកស្ថាបនិក សមាជិកកិត្តិយស និងសមាជិកសកម្ម មានសិទ្ធិអនុម័ត បោះឆ្នោតជ្រើសតាំងថ្នាក់ ដឹកនាំ ឬសម្រេចកិច្ចការនានារបស់គណបក្សបាន យោងតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស។

**ប្រការ ៤ ៖**

ថ្នាក់ដឹកនាំគណបក្សត្រូវជ្រើសរើសចេញពី សមាជិកស្ថាបនិក សមាជិកកិត្តិយស និងសមាជិកសកម្ម ដោយ យោងលើលក្ខណសម្បត្តិ ដូចខាងក្រោម៖

១. មានភាពស្មោះត្រង់ និងអនុវត្តតាមគោលការណ៍របស់គណបក្ស

២. មានការតស៊ូលះបង់ និងការទទួលខុសត្រូវខ្ពស់

៣. មានសមត្ថភាព លទ្ធភាព ឬបទពិសោធន៍ការងារ

៤. មានសុខភាពល្អ ទាំងផ្លូវកាយ និងផ្លូវចិត្ត

៥. មានគុណធម៌ និងសីលធម៌ល្អ

៦. មានប្រជាប្រិយភាព

៧. មាននីតិសម្បទាពេញលេញ(សិទ្ធិនយោបាយ)។

**ប្រការ ៥ ៖**

សមាជិកស្ថាបនិក សមាជិកកិត្តិយស និងសមាជិកសកម្មរបស់គណបក្ស អាចសុំលាចេញពីគណបក្សដោយ សេរី និងគ្មានការបង្ខិតបង្ខំ។ ការបញ្ចប់សមាជិកភាព ឬលុបឈ្មោះចេញពីបញ្ជីគណបក្ស ក្នុងករណីដែលសមាជិករូប

នោះបានប្រព្រឹត្តល្មើសនឹងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស ឬធ្វើសកម្មភាពទាំងឡាយណាដែលផ្ទុយនឹងផលប្រយោជន៍គណបក្ស ហើយត្រូវសម្រេច និងប្រកាសឡើងដោយៈ

- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត(ដោយមានការឯកភាពពីអគ្គលេខាធិការគណបក្ស) ចំពោះសមាជិកសកម្មថ្នាក់ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងភូមិនៅក្នុងរាជធានី-ខេត្តសាមី ហើយមានការបើកផ្លូវតវ៉ារយៈពេល ១៥ថ្ងៃ មកគណៈកម្មាធិការវិន័យរបស់គណបក្ស សេចក្តីសម្រេចរបស់គណៈកម្មាធិការវិន័យ គឺជាការបិទផ្លូវតវ៉ា។
- គណៈកម្មាធិការវិន័យគណបក្ស ចំពោះសមាជិកស្ថាបនិក សមាជិកកិត្តិយស ថ្នាក់ដឹកនាំគណបក្សថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត ហើយមានការបើកផ្លូវតវ៉ារយៈពេល ១៥ថ្ងៃ មកគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្ស សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គឺជាការបិទផ្លូវតវ៉ា។

នីតិវិធីនៃកិច្ចប្រជុំ និងការធ្វើសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត និងគណៈកម្មាធិការវិន័យគណបក្ស មានចែងនៅក្នុងជំពូកទី២ នៃបទបញ្ជាផ្ទៃក្នុងគណបក្ស។

## ជំពូកទី២
## រចនាសម្ព័ន្ធគណបក្ស

**ប្រការ ៦ ៖**

គណបក្សប្រជាធិបតេយ្យជឿនលឿន មានរចនាសម្ព័ន្ធ ដូចតទៅ ៖

១. សមាជ

២. ក្រុមប្រឹក្សាជាតិ

៣. គណៈកម្មាធិការនាយក

៤. គណៈកម្មាធិការវិន័យ

៥. គណៈកម្មាធិការប្រតិបត្តិ

៦. គណៈកម្មាធិការអចិន្ត្រៃយ៍

៧. រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ។

## ផ្នែកទី១
## សមាជគណបក្ស

**ប្រការ ៧ ៖**

សមាជគណបក្ស គឺជាស្ថាប័នកំពូលរបស់គណបក្ស ដើម្បីផ្តល់លទ្ធភាពឱ្យសមាជិកគណបក្ស ដែលមានលក្ខណៈជាតំណាង ហើយដែលត្រូវបានអនុញ្ញាតឱ្យចូលរួមសមាជ សម្តែងមតិយោបល់របស់ខ្លួន និងចូលរួមក្នុងការកំណត់ទិសដៅ និងគោលនយោបាយរបស់គណបក្ស ព្រមទាំងពិភាក្សា និងអនុម័តការងារសំខាន់ៗរបស់គណបក្ស ដូចមានចែងក្នុងប្រការ២០(ថ្មី) នៃលក្ខន្តិកៈ។

សមាជ មានពីរប្រភេទ គឺសមាជសាមញ្ញ និងសមាជវិសាមញ្ញ ត្រូវប្រារព្ធឡើងស្របតាមជំពូកទី៥ ផ្នែកទី១ នៃលក្ខន្តិកៈ។ សមាជទាំងពីរប្រភេទនេះ ត្រូវតែប្រារព្ធឡើងក្រោមអធិបតីភាពរបស់ប្រធានគណបក្ស ឬប្រធានសមាជ (សម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស)។

សមាជគណបក្ស គឺជាស្ថាប័នតែមួយគត់ ដែលមានសមត្ថកិច្ចធ្វើការកែប្រែលក្ខន្តិកៈ ឬរំលាយគណបក្ស។

ការកោះប្រជុំសមាជ ក្នុងគោលបំណងកែប្រែលក្ខន្តិកៈ ឬរំលាយគណបក្ស ត្រូវមានការយល់ព្រមដោយសំឡេងភាគច្រើន (២/៣) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ហើយត្រូវមានការយល់ព្រមពីប្រធានគណបក្ស និងប្រធានគណៈកម្មាធិការវិន័យ។

ការអនុម័ត ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ តាមរយៈការបោះឆ្នោតដោយលើកដៃ ដោយសំឡេងភាគច្រើន (២/៣) នៃសមាជិកដែលមានសិទ្ធិសម្រេច។

សមាជលើកទី១ ស្ថិតនៅក្រោមការចាត់ចែងរបស់គណៈកម្មាធិការបណ្ដោះអាសន្នរបស់គណបក្ស ស្របតាមជំពូកទី៨ និងជំពូកទី៩ នៃលក្ខន្តិកៈ។

**ប្រការ ៨ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស មានភារកិច្ចកោះប្រជុំ និងរៀបចំសមាជសាមញ្ញ និងវិសាមញ្ញ ស្របតាមប្រការ២១(ថ្មី) និងប្រការ២២ នៃលក្ខន្តិកៈ។ សមាជិកដែលអាចចូលរួមក្នុងសមាជបាន៖

- ប្រធាន និងអនុប្រធានគណបក្ស
- គណៈកម្មាធិការនាយក
- គណៈកម្មាធិការប្រតិបត្តិ
- គណៈកម្មាធិការវិន័យ
- ក្រុមប្រឹក្សាជាតិ
- និងប្រតិភូតំណាង កំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

**ប្រការ ៩ ៖**

សមាជជ្រើសតាំងប្រធានគណបក្ស តាមវិធីដែលមានចែងក្នុងជំពូកទី៥ ផ្នែកទី១ ប្រការ២០(ថ្មី) នៃលក្ខន្តិកៈ។ ការបោះឆ្នោតជ្រើសតាំងប្រធានគណបក្ស ត្រូវបោះឆ្នោតដោយផ្ទាល់ និងសម្ងាត់ពីសមាជិកដែលមានសិទ្ធិសម្រេច។

ករណីដែលមិនទាន់មានប្រធាន ឬប្រធានគណបក្សលាលែង ឬប្រធានបាត់បង់សមាជិកភាព សមាជត្រូវប្រព្រឹត្តទៅក្រោមប្រធានសមាជ(សម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស) ដើម្បីដឹកនាំរៀបចំបោះឆ្នោតជ្រើសតាំងប្រធានគណបក្ស ដូចមានចែងក្នុងប្រការ៤៧(ថ្មី) នៃលក្ខន្តិកៈ។

ករណីថ្នាក់ដឹកនាំថ្នាក់ជាតិរបស់គណបក្ស ត្រូវបាត់បង់សមត្ថភាពដឹកនាំគណបក្សទាំងស្រុង ថ្នាក់ដឹកនាំសំខាន់ៗរបស់គណបក្ស ដែលនៅមានសមត្ថភាព ឬថ្នាក់ដឹកនាំថ្នាក់ក្រោមជាតិ ឬស្ថាបនិករបស់គណបក្ស ត្រូវបង្កើតគណៈកម្មាការបណ្ដោះអាសន្នមួយ ដូចមានចែងក្នុងជំពូកទី៩ នៃលក្ខន្តិកៈ ដើម្បីរៀបចំសម្រេចដឹកនាំគណបក្សបន្ត។

**ប្រការ ១០ ៖**

ប្រធានសមាជ បង្ហាញបញ្ជីសមាសភាពក្រុមប្រឹក្សាជាតិ ដែលជ្រើសរើសតាមស្មារតីនៃជំពូកទី៥ ផ្នែកទី២ នៃលក្ខន្តិកៈ។ សមាជផ្ដល់សេចក្ដីទុកចិត្តដល់បញ្ជីសមាសភាពក្រុមប្រឹក្សាជាតិ តាមរយៈការបោះឆ្នោតដោយលើកដៃ ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១)នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច។

**ប្រការ ១១ ៖**

ប្រធានសមាជ បង្ហាញបញ្ជីសមាសភាពគណៈកម្មាធិការនាយក ដែលជ្រើសរើសតាមស្មារតីនៃជំពូកទី៥ ផ្នែកទី៣ នៃលក្ខន្តិកៈ។ សមាជផ្ដល់សេចក្ដីទុកចិត្តដល់បញ្ជីសមាសភាពគណៈកម្មាធិការនាយក តាមរយៈការបោះឆ្នោតដោយលើកដៃ ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច។

**ប្រការ ១២ ៖**

សមាជអាចប្រព្រឹត្តទៅបាន ចាំបាច់ត្រូវមានកូរ៉ុមភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកក្រុមប្រឹក្សាជាតិទាំងមូល។ ក្នុងករណីមិនគ្រប់កូរ៉ុម ត្រូវរៀបចំលិខិតអញ្ជើញជាលើកទី២ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ ក្នុងរយៈពេលយ៉ាងតិច ៧ថ្ងៃមុនថ្ងៃសមាជ ដែលនឹងប្រព្រឹត្តទៅដោយពុំគិតកូរ៉ុម។

ការបោះឆ្នោតដើម្បីអនុម័តសេចក្តីសម្រេចនានា ដែលគណៈកម្មាធិការនាយក ឬក្រុមប្រឹក្សាជាតិបានដាក់ជូនសមាជ តាមរយៈការបោះឆ្នោតដោយលើកដៃ ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច លើកលែងតែក្នុងប្រការដែលមានចែងផ្ទុយពីនេះ។

## ផ្នែកទី២

## ក្រុមប្រឹក្សាជាតិ

**ប្រការ ១៣ ៖**

ក្រុមប្រឹក្សាជាតិ គឺជាស្ថាប័នជាន់ខ្ពស់របស់គណបក្ស អាចជួបប្រជុំ២ឆ្នាំម្តង ហៅថាសន្និបាតក្រុមប្រឹក្សាជាតិ។ ក្រុមប្រឹក្សាជាតិ ជាប្រតិភូតំណាងឱ្យសមាជិកគណបក្សពីមូលដ្ឋាន និងមជ្ឈដ្ឋាននានា ទទួលស្គាល់ដោយសមាជ ដើម្បីចូលរួមសមាជ ឬសន្និបាតក្រុមប្រឹក្សាជាតិ និងមានតួនាទី ភារកិច្ចសំខាន់ៗ ស្របតាមជំពូកទី៥ ផ្នែកទី២ នៃលក្ខន្តិកៈ។

សន្និបាតក្រុមប្រឹក្សាជាតិ ត្រូវប្រារព្ធឡើងក្រោមអធិបតីភាពរបស់ប្រធានគណបក្ស ឬប្រធានសន្និបាត(សម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស) ដើម្បី ៖

- ធ្វើការពិភាក្សា អនុម័ត ឬផ្តល់សេចក្តីទុកចិត្ត លើសេចក្តីសម្រេចនានារបស់គណបក្ស ដែលដាក់ជូនដោយគណៈកម្មាធិការនាយក ចន្លោះសមាជ
- អនុម័តគោលនយោបាយសំខាន់ៗរបស់គណបក្ស។

**ប្រការ ១៤ ៖**

ក្រុមប្រឹក្សាជាតិ មានសមាជិកយ៉ាងតិច ២៧រូប។ សមាសភាពក្រុមប្រឹក្សាជាតិតំណាងពី ៖

- គណៈកម្មាធិការអចិន្ត្រៃយ៍ (យ៉ាងតិច ៣នាក់)
- គណៈកម្មាធិការនាយក (យ៉ាងតិច ៣នាក់)
- គណៈកម្មាធិការវិន័យ (យ៉ាងតិច ២នាក់)
- គណៈកម្មាធិការប្រតិបត្តិ (យ៉ាងតិច ៧នាក់)
- ក្រុមការងាររាជធានី-ខេត្ត (យ៉ាងតិច ៣នាក់)
- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត (យ៉ាងតិច ៣នាក់)
- ប្រធាន និងអនុប្រធាន ចលនាមហាជនថ្នាក់ជាតិ (យ៉ាងតិច ៣នាក់)
- ប្រធានគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ (យ៉ាងតិច ៣នាក់)

សមាសភាពក្រុមប្រឹក្សាជាតិនេះ កំណត់ដូចមានចែងក្នុងប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈគណបក្ស និងត្រូវបានផ្តល់សេចក្តីទុកចិត្តដោយសមាជគណបក្ស។

អនុលោមតាមប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈ តាមសំណើរបស់ប្រធានគណបក្ស ឬ១/៤ នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ១/៤ នៃគណៈកម្មាធិការនាយក ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់មុនពេល ឬចន្លោះសមាជ គណៈកម្មាធិការនាយកសម្រេចដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) ក្នុងការដកតួនាទី ឬជ្រើសតាំងបន្ថែមសមាជិកក្រុមប្រឹក្សាជាតិ។

**ប្រការ ១៥ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ដែលមានភារៈកិច្ចរៀបចំសន្និបាតក្រុមប្រឹក្សាជាតិ ត្រូវរៀបចំលិខិតអញ្ជើញអ្នកចូលរួមសន្និបាតក្រុមប្រឹក្សាជាតិ ដោយមានបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ ក្នុងរយៈពេលយ៉ាងតិច ១៥ថ្ងៃមុនថ្ងៃសន្និបាតក្រុមប្រឹក្សាជាតិ។

សន្និបាតក្រុមប្រឹក្សាជាតិអាចប្រព្រឹត្តទៅបាន ចាំបាច់ត្រូវមានកូរ៉ុមភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកក្រុមប្រឹក្សាជាតិទាំងមូល។ ក្នុងករណីមិនគ្រប់កូរ៉ុម ត្រូវរៀបចំលិខិតអញ្ជើញជាលើកទី២ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ ក្នុងរយៈពេលយ៉ាងតិច ៧ថ្ងៃមុនថ្ងៃសន្និបាតក្រុមប្រឹក្សាជាតិ ដែលនឹងប្រព្រឹត្តទៅដោយពុំគិតកូរ៉ុម។

សេចក្តីសម្រេចរបស់សន្និបាតក្រុមប្រឹក្សាជាតិ ត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច លើកលែងតែក្នុងប្រការដែលមានចែងផ្ទុយពីនេះ។

## ផ្នែកទី៣

## គណៈកម្មាធិការនាយក

**ប្រការ ១៦ ៖**

គណៈកម្មាធិការនាយក គឺជាស្ថាប័ននីតិប្បញ្ញត្តិរបស់គណបក្ស កើតចេញពីសមាជ និងមានតួនាទី ភារកិច្ចសំខាន់ៗ ស្របតាមជំពូកទី៥ ផ្នែកទី៣ នៃលក្ខន្តិកៈ ៖

- អនុវត្តតាមទិសដៅ និងគោលនយោបាយរបស់គណបក្ស ដែលកំណត់ដោយសមាជ ឬសន្និបាតក្រុមប្រឹក្សាជាតិ
- ពិភាក្សា អនុម័ត រាល់បទប្បញ្ញត្តិផ្សេងៗរបស់គណបក្ស តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍
- ត្រួតពិនិត្យការប្រតិបត្តិរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស និងអាចផ្តួចផ្តើមគំនិតឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍ដឹកនាំគណបក្សស្របតាមស្ថានការណ៍ និងកាលៈទេសៈជាក់ស្តែងដើម្បីឱ្យគណបក្ស មានការរីកចម្រើន
- បង្កើតគណៈកម្មាធិការវិន័យគណបក្សដូចមានចែងក្នុងជំពូកទី៥ ផ្នែកទី៤ នៃលក្ខន្តិកៈ
- ជ្រើសតាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស
- ផ្តល់សេចក្តីទុកចិត្តដល់សមាសភាពគណៈកម្មាធិការប្រតិបត្តិថ្នាក់ជាតិ តាមសំណើរបស់ប្រធានគណបក្ស
- អាចបង្កើតគណៈកម្មការនានាតាមតម្រូវការចាំបាច់ ដើម្បីភាពរីកចម្រើនរបស់គណបក្ស ជាពិសេសដើម្បីសិក្សាស្រាវជ្រាវចងក្រងឯកសារពី សង្គម សេដ្ឋកិច្ច នយោបាយ ច្បាប់ ទុកជាជំនួយដល់គណៈកម្មាធិការនាយក ក្នុងការរៀបចំគោលនយោបាយគណបក្ស។

**ប្រការ ១៧ ៖**

គណៈកម្មាធិការនាយក មានសមាជិកយ៉ាងតិច ២៥រូប ដែលផ្តល់សេចក្តីទុកចិត្តដោយសមាជគណបក្សសម្រាប់អាណត្តិ៥ឆ្នាំ។ សមាជិកគណៈកម្មាធិការនាយកត្រូវបានជ្រើសរើសពី ៖

- ក្រុមប្រឹក្សាជាតិ និងក្រុមការងាររាជធានី-ខេត្ត។ ចំនួនបេក្ខជនគណៈកម្មាធិការនាយក តំណាងគណបក្សរាជធានី-ខេត្តនីមួយៗ មានចំនួនយ៉ាងច្រើនស្មើនឹងអាសនៈតំណាងរាស្ត្រក្នុងរាជធានី-ខេត្តសាមី បូកមួយចែកនឹងពីរ ដោយសំឡេងគាំទ្រភាគច្រើនតាមលំដាប់។
- តាមសំណើរបស់ប្រធានគណបក្ស ហើយចំនួនបេក្ខជនគណៈកម្មាធិការនាយកដែលជ្រើសរើសនេះ មិនត្រូវលើសចំនួន ១/៣ នៃសមាជិកគណៈកម្មាធិការនាយកមកពីតំណាងគណបក្ស រាជធានី-ខេត្ត ហើយត្រូវ

ផ្តល់អាទិភាពដល់យុវជន ស្ត្រី និងតំណាងសាខាគណបក្សក្រៅប្រទេស តាមរយៈការបោះឆ្នោតសម្ងាត់ ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

**ប្រការ ១៨ ៖**

អនុលោមតាមប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈ តាមសំណើរបស់ប្រធានគណបក្ស ឬ១/៤នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ១/៤នៃគណៈកម្មាធិការនាយក ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់មុនពេល ឬចន្លោះសមាជ គណៈកម្មាធិការនាយកសម្រេចដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) ក្នុងការដកតួនាទី ឬជ្រើសតាំងបន្ថែម សមាជិកគណៈកម្មាធិការនាយក។

**ប្រការ ១៩ ៖**

សមាជិកគណៈកម្មាធិការនាយក ត្រូវបានបញ្ចប់មុខងារ ដូចមានចែងក្នុងប្រការ១៦ និងប្រការ១៧ នៃលក្ខន្តិកៈ។ សមាជិកគណៈកម្មាធិការនាយក អាចបាត់បង់សមាជិកភាពរបស់ខ្លួនដោយ ៖

- មរណភាព
- ការសុំលាលែងជាលាយលក្ខណ៍អក្សរ ដាក់ជូនប្រធានគណបក្ស
- ការបញ្ចប់សមាជិកភាពពីគណបក្ស
- អវត្តមានក្នុងកិច្ចប្រជុំរបស់ខ្លួនចំនួន៣ដងជាបន្តបន្ទាប់ ដោយគ្មានការជូនដំណឹង ត្រូវព្រមានជាលាយលក្ខណ៍ អក្សរពីប្រធានគណៈកម្មាធិការនាយក។ ប្រសិនបើនៅបន្តអវត្តមានក្នុងកិច្ចប្រជុំ ដោយគ្មានការជូនដំណឹង ចំនួន៣ដងជាបន្តបន្ទាប់ទៀត ត្រូវបាត់បង់តួនាទីពីគណៈកម្មាធិការនាយក ដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការនាយក អាចរៀបចំបំពេញបន្ថែមសមាជិកគណៈកម្មាធិការនាយក ស្របតាមប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈ។

**ប្រការ ២០ ៖**

គណៈកម្មាធិការនាយក ដឹកនាំដោយប្រធាន មួយរូប និងអនុប្រធាន យ៉ាងតិចមួយរូប។

គណៈកម្មាធិការនាយក ត្រូវមានលេខាធិការដ្ឋានមួយ ជាសេនាធិការរបស់ខ្លួន។ រាល់ការប្រជុំរបស់គណៈកម្មាធិការនាយកត្រូវមានលិខិតអញ្ជើញពីប្រធាន ឬប្រធានស្តីទីរបស់គណៈកម្មាធិការនាយក ឬប្រធានគណបក្ស ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមទូរសព្ទ ដោយបញ្ជាក់នូវកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ យ៉ាងតិច ៣ថ្ងៃមុនថ្ងៃប្រជុំ។

ការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋាន កំណត់ដោយគណៈកម្មាធិការនាយក។

**ប្រការ ២១ ៖**

ប្រធានគណៈកម្មាធិការនាយក ជ្រើសតាំងដោយសមាជិកគណៈកម្មាធិការនាយក តាមរយៈការបោះឆ្នោតសម្ងាត់ ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

បេក្ខជនប្រធានគណៈកម្មាធិការនាយក ជាសមាជិកគណៈកម្មាធិការនាយក ដែលមានការគាំទ្រពីសមាជិកគណៈកម្មាធិការនាយកចំនួនយ៉ាងតិច ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

អនុប្រធានគណៈកម្មាធិការនាយក ជាសមាជិកគណៈកម្មាធិការនាយក ត្រូវបានផ្តល់ការយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល តាមសំណើរបស់ប្រធានគណៈកម្មាធិការនាយក។

**ប្រការ ២២ ៖**

ប្រធានគណៈកម្មាធិការនាយក គឺជាប្រធាននៃកិច្ចប្រជុំរបស់គណៈកម្មាធិការនាយក។

រាល់ការផ្ទេរសិទ្ធិពីប្រធានគណៈកម្មាធិការនាយក ឱ្យដឹកនាំការប្រជុំជំនួស ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយចំពោះ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងត្រូវជូនដំណឹងទៅប្រធានគណបក្ស។

គណៈកម្មាធិការនាយក ជួបប្រជុំគ្នាយ៉ាងតិច៣ខែម្តង។ ក្នុងករណីចាំបាច់ ប្រធានគណបក្ស ឬប្រធានគណៈកម្មាធិការនាយក ឬសំណើ ១/៣ នៃសមាជិកគណៈកម្មាធិការនាយក មានសិទ្ធិកោះប្រជុំគណៈកម្មាធិការនាយក។

កិច្ចប្រជុំរបស់គណៈកម្មាធិការនាយក ត្រូវមានកូរ៉ុម (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។ ក្នុងករណីមិនគ្រប់កូរ៉ុម ត្រូវរៀបចំអញ្ជើញជាលើកទី២ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ ក្នុងរយៈពេលយ៉ាងតិច៣ថ្ងៃមុនថ្ងៃប្រជុំ ដែលនឹងប្រព្រឹត្តទៅដោយពុំគិតកូរ៉ុម។

សេចក្តីសម្រេចរបស់កិច្ចប្រជុំ ត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច។

សមាជិកគណៈកម្មាធិការនាយកដែលអវត្តមាន ដោយមានការអនុញ្ញាតពីប្រធានគណៈកម្មាធិការនាយក មានសិទ្ធិបោះឆ្នោតតាមរយៈការផ្ទេរសិទ្ធិជាលាយលក្ខអក្សរ ឬតាមអេឡិចត្រូនិក ជូនសមាជិកគណៈកម្មាធិការនាយកណាម្នាក់ដែលមានវត្តមាន។

**ប្រការ ២៣ ៖**

គណៈកម្មាធិការនាយក អាចបើកឱ្យជជែកដេញដោល ឬសុំបំភ្លឺពីបញ្ហាអ្វីមួយពីគណៈកម្មាធិការប្រតិបត្តិ តាមការស្នើសុំពីសមាជិក១/៤ នៃសមាជិកគណៈកម្មាធិការនាយក តាមរយៈប្រធានគណៈកម្មាធិកានាយក។ ករណីនេះប្រធានគណៈកម្មាធិការប្រតិបត្តិមកបំភ្លឺដោយផ្ទាល់ ឬអាចចាត់តាំងតំណាងម្នាក់មកឆ្លើយបំភ្លឺបាន។

## ផ្នែកទី៤
## គណៈកម្មាធិការវិន័យ

**ប្រការ ២៤ ៖**

គណៈកម្មាធិការវិន័យ គឺជាស្ថាប័នដោះស្រាយវិវាទរបស់គណបក្ស ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការនាយក និងមានតួនាទី ភារកិច្ចសំខាន់ៗ ស្របតាមជំពូកទី៥ ផ្នែកទី៤ នៃលក្ខន្តិកៈ ៖

- ទទួលពាក្យបណ្តឹងវិវាទរបស់សមាជិកគណបក្ស
- ទទួលពាក្យបណ្តឹងស្តីពីភាពមិនប្រក្រតី នៃចំណូល-ចំណាយរបស់គណបក្ស
- ទទួលបណ្តឹងឧទ្ធរណ៍ ករណីបញ្ចប់សមាជិកភាពដោយគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត
- ដាក់វិន័យសមាជិកគណបក្សណា ដែលរំលោភបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ១៨ នៃលក្ខន្តិកៈ។

**ប្រការ ២៥ ៖**

គណៈកម្មាធិការវិន័យ មានប្រធានមួយរូប អនុប្រធានមួយរូប ជ្រើសរើសដោយគណៈកម្មាធិការនាយក ពីក្នុងចំណោមសមាជិករបស់ខ្លួន តាមរយៈការបោះឆ្នោតដោយលើកដៃ ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកគណៈកម្មាធិការនាយកទាំងមូល។

សមាជិកគណៈកម្មាធិការវិន័យប្រាំរូបទៀត ដែលស្នើឡើងដោយប្រធានគណៈកម្មាធិការវិន័យ ពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាតិ ដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកគណៈកម្មាធិការនាយកទាំងមូល។

បេក្ខជនប្រធាន និងអនុប្រធាន ត្រូវមានការគាំទ្រពីសមាជិកគណៈកម្មាធិការនាយកចំនួនយ៉ាងតិច ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

អនុលោមតាមប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈ តាមសំណើរបស់ប្រធានគណបក្ស ឬ១/៤ នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ១/៤ នៃគណៈកម្មាធិការនាយក ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់មុនពេល ឬចន្លោះសមាជ គណៈកម្មាធិការនាយកសម្រេចដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) ក្នុងការដកតួនាទី ឬជ្រើសតាំងបង្គ្រប់សមាជិកគណៈកម្មាធិការវិន័យ។

**ប្រការ ២៦ ៖**

សមាជិកគណៈកម្មាធិការវិន័យ ត្រូវបានបញ្ចប់មុខងារ ដូចមានចែងក្នុងប្រការ១៦ និងប្រការ១៧ នៃលក្ខន្តិកៈ។ សមាជិកគណៈកម្មាធិការវិន័យ អាចបាត់បង់សមាជិកភាពរបស់ខ្លួនដោយ ៖

- មរណភាព
- ការសុំលាលែងជាលាយលក្ខណ៍អក្សរ ដាក់ជូនប្រធានគណបក្ស
- ការបញ្ចប់សមាជិកភាពពីគណបក្ស។
- អវត្តមានក្នុងកិច្ចប្រជុំរបស់ខ្លួនចំនួន៣ដងជាបន្តបន្ទាប់ ដោយគ្មានការជូនដំណឹង ត្រូវព្រមានជាលាយលក្ខណ៍អក្សរពីប្រធានគណៈកម្មាធិការវិន័យ។ ប្រសិនបើនៅបន្តអវត្តមានក្នុងកិច្ចប្រជុំ ដោយគ្មានការជូនដំណឹងចំនួន៣ដងជាបន្តបន្ទាប់ទៀត ត្រូវបាត់បង់តួនាទីពីគណៈកម្មាធិការវិន័យ ដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការវិន័យ អាចស្នើសុំឱ្យគណៈកម្មាធិការនាយក រៀបចំបំពេញបន្ថែមសមាជិកគណៈកម្មាធិការវិន័យ ស្របតាមប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈ។

**ប្រការ ២៧ ៖**

គណៈកម្មាធិការវិន័យ ត្រូវមានលេខាធិការដ្ឋានមួយ ជាសេនាធិការរបស់ខ្លួន។ រាល់ការប្រជុំរបស់គណៈកម្មាធិការវិន័យត្រូវមានលិខិតអញ្ជើញពីប្រធាន ឬប្រធានស្តីទីរបស់គណៈកម្មាធិការវិន័យ ឬប្រធានគណបក្ស ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមទូរសព្ទ ដោយបញ្ជាក់នូវកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ យ៉ាងតិច៣ថ្ងៃមុនថ្ងៃប្រជុំ។

ការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋាន កំណត់ដោយគណៈកម្មាធិការវិន័យ។

**ប្រការ ២៨ ៖**

ប្រធានគណៈកម្មាធិការវិន័យ គឺជាប្រធាននៃកិច្ចប្រជុំរបស់គណៈកម្មាធិការវិន័យ។

រាល់ការផ្ទេរសិទ្ធិពីប្រធានគណៈកម្មាធិការវិន័យ ឱ្យដឹកនាំការប្រជុំជំនួស ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយចំពោះ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងត្រូវជូនដំណឹងទៅប្រធានគណបក្ស។

គណៈកម្មាធិការវិន័យប្រជុំសាមញ្ញ៣ខែម្តង។ ការប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការវិន័យ អាចធ្វើទៅបានដោយមានការស្នើសុំពីប្រធានគណបក្ស ឬសំណើ ១/៣ នៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬប្រធានគណៈកម្មាធិការវិន័យ ឬប្រធានគណៈកម្មាធិការនាយក ពេលមានបញ្ហាណាមួយដែលត្រូវដោះស្រាយ។

កិច្ចប្រជុំរបស់គណៈកម្មាធិការវិន័យ ត្រូវមានកូរ៉ុម (៥០%+១) នៃសមាជិកគណៈកម្មាធិការវិន័យទាំងមូល។ ក្នុងករណីមិនគ្រប់កូរ៉ុម ត្រូវរៀបចំអញ្ជើញជាលើកទី២ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ ក្នុងរយៈពេលយ៉ាងតិច៣ថ្ងៃមុនថ្ងៃប្រជុំ ដែលនឹងប្រព្រឹត្តទៅដោយពុំគិតកូរ៉ុម។

សេចក្តីសម្រេចរបស់កិច្ចប្រជុំ ត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច។

សមាជិកគណៈកម្មាធិការវិន័យដែលអវត្តមាន ដោយមានការអនុញ្ញាតពីប្រធានគណៈកម្មាធិការវិន័យ មានសិទ្ធិបោះឆ្នោតតាមរយៈការផ្ទេរសិទ្ធិជាលាយលក្ខអក្សរ ឬតាមអេឡិចត្រូនិក ជូនសមាជិកគណៈកម្មាធិការវិន័យណាម្នាក់ដែលមានវត្តមាន។

**ប្រការ ២៩ ៖**

រាល់វិវាទទាំងអស់អាចប្ដឹងចូលមកគណៈកម្មាធិការវិន័យបាន បន្ទាប់ពីការដោះស្រាយតាមរយៈអង្គភាពនីមួយៗមិនបានសម្រេច។ ការដោះស្រាយវិវាទត្រូវធ្វើទៅតាមនីតិវិធីដូចតទៅ៖

- ត្រូវមានពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរពីសមាជិកណាម្នាក់ ប្ដឹងទៅគណៈកម្មាធិការវិន័យ ដោយបញ្ជាក់ពីហេតុផលភ្ជាប់មកជាមួយនូវភស្តុតាងផ្តិតមេដៃ ឬចុះហត្ថលេខា និងឈ្មោះដើមបណ្ដឹង
- ៧ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលពាក្យបណ្ដឹង គណៈកម្មាធិការវិន័យត្រូវចាត់វិធានការធ្វើការស៊ើបអង្កេត រួមទាំងកោះហៅដើមចោទ ចុងចោទ ព្រមទាំងសាក្សី និងភាគីពាក់ព័ន្ធចូលមកបំភ្លឺ
- ករណីដើមចោទមិនបានចូលខ្លួនតាមការកោះហៅលើកទី១ គណៈកម្មាធិការវិន័យត្រូវកោះហៅជាលើកទី២ បន្ទាប់ពីរយៈពេល៧ថ្ងៃ។ បើដើមចោទនៅតែមិនចូលមកតាមការកោះហៅនេះទៀត គណៈកម្មាធិការវិន័យចាត់ទុកថាសាមីខ្លួនបោះបង់បណ្ដឹងរបស់ខ្លួន
- ករណីចុងចោទមិនបានចូលខ្លួនតាមការកោះហៅលើកទី១ គណៈកម្មាធិការវិន័យត្រូវកោះហៅជាលើកទី២ បន្ទាប់ពីរយៈពេល៧ថ្ងៃ។ បើចុងចោទនៅតែមិនចូលមកតាមការកោះហៅនេះទៀត គណៈកម្មាធិការវិន័យអាចធ្វើការពិនិត្យ និងសម្រេចដោយកំបាំងមុខ។

**ប្រការ ៣០ ៖**

សេចក្ដីសម្រេចរបស់គណៈកម្មាធិការវិន័យ ជាសេចក្ដីសម្រេចចុងក្រោយ និងបិទផ្លូវតវ៉ា លើកលែងតែការបញ្ចប់សមាជិកភាពថ្នាក់ដឹកនាំគណបក្សថ្នាក់ជាតិ និងថ្នាក់ដឹកនាំថ្នាក់រាជធានី-ខេត្ត ដែលមានចែងក្នុងប្រការ១៧ នៃលក្ខន្តិកៈ។

## ផ្នែកទី៥
## គណៈកម្មាធិការប្រតិបត្តិ

**ប្រការ ៣១ ៖**

គណៈកម្មាធិការប្រតិបត្តិ គឺជាស្ថាប័ននីតិប្រតិបត្តិរបស់គណបក្ស អនុវត្តកិច្ចការប្រចាំថ្ងៃរបស់គណបក្ស តាមសេចក្ដីសម្រេចរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការនាយក។

គណៈកម្មាធិការប្រតិបត្តិគ្រប់គ្រង និងជានាការប្រព្រឹត្តទៅរបស់គណបក្ស ព្រមទាំងរចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ និងសាខាគណបក្សនៅក្រៅប្រទេស។

ប្រធាន អនុប្រធាន និងអគ្គលេខាធិការគណៈកម្មាធិការប្រតិបត្តិ ជាប្រធាន អនុប្រធាន និងអគ្គលេខាធិការគណបក្ស។

គណៈកម្មាធិការប្រតិបត្តិ មានសមាសភាពជ្រើសចេញមកពីសមាជិកគណៈកម្មាធិការនាយកដូចមានចែងក្នុងប្រការ៣៧ នៃលក្ខន្តិកៈ។

**ប្រការ ៣២ ៖**

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ហេរញ្ញិក ហេរញ្ញិករង ស្នើសុំតែងតាំងដោយ ប្រធានគណៈកម្មាធិការប្រតិបត្តិ ហើយត្រូវផ្ដល់សេចក្ដីទុកចិត្តពីគណៈកម្មាធិការនាយក ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

អនុប្រធានគណៈកម្មាធិការប្រតិបត្តិ ទទួលការងារតាមការកំណត់របស់ប្រធានគណៈកម្មាធិការប្រតិបត្តិ។

គណៈកម្មាធិការប្រតិបត្តិ មានអគ្គលេខាធិការដ្ឋាន ជាសេនាធិការ។

**ប្រការ ៣៣ ៖**

អគ្គលេខាធិការដ្ឋាន ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរង យ៉ាងតិចមួយរូប។

អគ្គលេខាធិការដ្ឋាន មាននាយកដ្ឋានមួយចំនួនតាមតម្រូវការចាំបាច់។ នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប ដែលតែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិ តាមសំណើរបស់អគ្គលេខាធិការ។

ការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋាន កំណត់ដោយគណៈកម្មាធិការប្រតិបត្តិ។

នៅពេលអវត្តមានអគ្គលេខាធិការ អគ្គលេខាធិការរងមួយរូបត្រូវបានប្រគល់សិទ្ធិដោយអគ្គលេខាធិការ ជាអគ្គលេខាធិការស្តីទី។

**ប្រការ ៣៤ ៖**

នាយកដ្ឋានហិរញ្ញវត្ថុ ដឹកនាំដោយហេរញ្ញិកមួយរូប អមដោយហេរញ្ញិករងមួយរូប។

ហេរញ្ញិក ទទួលបន្ទុកគ្រប់គ្រងថវិកា និងបញ្ជីសារពើភណ្ឌទាំងអស់របស់គណបក្ស។

ហេរញ្ញិក ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្តីពីប្រាក់ចំណូល-ចំណាយរបស់គណបក្ស ជូនអគ្គលេខាធិការ និងប្រធានគណៈកម្មាធិការប្រតិបត្តិ។

**ប្រការ ៣៥ ៖**

គណបក្សត្រូវមានគណនីធនាគារមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកដែលមានសិទ្ធិបើកប្រាក់មានពីររូប គឺប្រធាន ឬអនុប្រធានគណបក្ស ឬអគ្គលេខាធិការ និងហេរញ្ញិក។

គណបក្សអាចមានគណនីធនាគារនៅតាមរាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកមានសិទ្ធិបើកប្រាក់មានពីររូប គឺប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត និងហេរញ្ញិករាជធានី-ខេត្ត។

**ប្រការ ៣៦ ៖**

សមាជិកគណៈកម្មាធិការប្រតិបត្តិ ត្រូវបានបញ្ចប់មុខងារ ដូចមានចែងក្នុងប្រការ១៦ និងប្រការ១៧ នៃលក្ខន្តិកៈ។ សមាជិកគណៈកម្មាធិការប្រតិបត្តិ អាចបាត់បង់សមាជិកភាពរបស់ខ្លួនដោយ ៖

- មរណភាព
- ការសុំលាលែងជាលាយលក្ខណ៍អក្សរ ដាក់ជូនប្រធានគណបក្ស
- ការបញ្ចប់សមាជិកភាពពីគណបក្ស។
- អវត្តមានក្នុងកិច្ចប្រជុំរបស់ខ្លួនចំនួន៣ដងជាបន្តបន្ទាប់ ដោយគ្មានការជូនដំណឹង ត្រូវព្រមានជាលាយលក្ខណ៍អក្សរពីប្រធានគណៈកម្មាធិការប្រតិបត្តិ។ ប្រសិនបើនៅបន្តអវត្តមានក្នុងកិច្ចប្រជុំ ដោយគ្មានការជូនដំណឹងចំនួន៣ដងជាបន្តបន្ទាប់ទៀត ត្រូវបាត់បង់តួនាទីពីគណៈកម្មាធិការប្រតិបត្តិ ដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការប្រតិបត្តិ អាចស្នើសុំឱ្យគណៈកម្មាធិការនាយក រៀបចំបំពេញបន្ថែមសមាជិកគណៈកម្មាធិការប្រតិបត្តិ ស្របតាមប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈ។

## ផ្នែកទី៦
## គណៈកម្មាធិការអចិន្ត្រៃយ៍

**ប្រការ ៣៧ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍ដឹកនាំ ចាត់ចែង និងអនុវត្តកិច្ចការប្រចាំថ្ងៃរបស់គណបក្ស ស្របតាមជំពូកទី៥ ផ្នែកទី៦ នៃលក្ខន្តិកៈ។

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស រៀបចំគម្រោងផែនការសំខាន់ៗ ដាក់ជូនគណៈកម្មាធិការនាយកពិនិត្យមុននឹងដាក់ជូនសមាជ ឬសន្និបាតក្រុមប្រឹក្សាជាតិ ពិភាក្សា និងអនុម័ត។

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស មានចំនួនយ៉ាងច្រើន ២៧រូប ដែលមានសមាសភាពដូចតទៅ ៖

- ប្រធាន និងអនុប្រធានគណបក្ស
- ប្រធាន គណៈកម្មាធិការនាយក
- ប្រធាន គណៈកម្មាធិការវិន័យ
- អគ្គលេខាធិការ
- និងសមាជិកមួយចំនួន ដែលជ្រើសរើសដោយគណៈកម្មាធិការនាយក ពីក្នុងចំណោមសមាជិករបស់ខ្លួន តាមសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

ប្រធាន និងអនុប្រធានគណបក្ស ជាប្រធាន និងអនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍។

កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ អាចប្រព្រឹត្តទៅបានតាមការសម្រេចរបស់ប្រធាន ឬតាមសំណើចំនួន ១/៣ នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយចាំបាច់ត្រូវមានកូរ៉ុម ២/៣ នៃសមាជិកទាំងមូល។

សេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវមានសំឡេងគាំទ្រភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកទាំងមូល។

គណៈកម្មាធិការអចិន្ត្រៃយ៍ ជួបប្រជុំគ្នាយ៉ាងតិច៣ខែម្ដង។ ប្រធាន ឬអនុប្រធាន អាចកោះប្រជុំបានតាមតម្រូវការចាំបាច់។

**ប្រការ ៣៨ ៖**

ប្រធានគណបក្ស ត្រូវបានជ្រើសតាំងដោយសមាជ តាមរយៈការអនុម័តសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច សម្រាប់អាណត្តិ៥ឆ្នាំ។

បេក្ខជនប្រធានគណបក្ស ជាសមាជិកគណៈកម្មាធិការនាយក ហើយត្រូវមានការគាំទ្រពីសមាជិកគណៈកម្មាធិការនាយក ចំនួនយ៉ាងតិច ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

ឥស្សរជននយោបាយមួយរូប ជាសមាជិកគណៈកម្មាធិការនាយកក្នុងគណបក្ស អាចធ្វើជាប្រធានគណបក្ស ត្រឹមពីរអាណត្តិ(១០ឆ្នាំ)។

**ប្រការ ៣៩ ៖**

ប្រធានគណបក្ស មានខុទ្ទកាល័យមួយ ដើម្បីជួយដល់កិច្ចការផ្ទាល់របស់ខ្លួន។ ខុទ្ទកាល័យប្រធានគណបក្ស ដឹកនាំដោយនាយខុទ្ទកាល័យមួយរូប អមដោយនាយរងខុទ្ទកាល័យមួយចំនួនដែលតែងតាំងដោយប្រធានគណបក្ស។

ប្រធានគណបក្ស មានសិទ្ធិបង្កើតក្រុមប្រឹក្សាយុទ្ធសាស្ត្រនយោបាយ តាមតម្រូវការចាំបាច់របស់គណបក្ស។

ប្រធានគណបក្ស តែងតាំង ឬផ្លាស់ប្ដូរបេក្ខជនតំណាងរាស្ត្រ បេក្ខជនសមាជិកព្រឹទ្ធសភា និងបេក្ខជន ថ្នាក់ដឹកនាំ ដទៃទៀត តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

ប្រធានគណបក្ស មានសិទ្ធិតែងតាំង ឬបញ្ចប់តួនាទី បេសកជន និងទីប្រឹក្សាផ្ទាល់របស់ខ្លួន។

ប្រធាន អនុប្រធានចលនាមហាជនថ្នាក់ជាតិ តែងតាំងដោយប្រធានគណបក្ស តាមសេចក្ដីសម្រេចរបស់ចលនាមហាជន។

**ប្រការ ៤០ ៖**

ខុទ្ទកាល័យមានភារកិច្ចៈ

- តាមដានសភាពការណ៍នយោបាយ សេដ្ឋកិច្ច និងសង្គម ដើម្បីរៀបចំផែនការនយោបាយ សេដ្ឋកិច្ច សង្គម ជូនប្រធានគណបក្ស
- រៀបចំឯកសារ និងពិធីការ
- ផ្តល់មតិយោបល់ជុំវិញការដឹកនាំរបស់គណបក្ស

**ប្រការ ៤១ ៖**

អនុប្រធានគណបក្ស ជាសមាជិកគណៈកម្មាធិការនាយក ត្រូវបានផ្តល់ការយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល តាមសំណើរបស់ប្រធានគណបក្ស។

អនុប្រធានគណបក្ស ទទួលដឹកនាំការងារគណបក្ស តាមការកំណត់របស់ប្រធានគណបក្ស។

នៅពេលអវត្តមានប្រធាន អនុប្រធានមួយរូប ត្រូវបានទទួលសិទ្ធិជាប្រធានស្តីទីគណបក្ស តាមរយៈលិខិតផ្ទេរសិទ្ធិ ដែលមានបុព្វសិទ្ធិ ដូចប្រធានគណបក្ស។

ក្នុងករណីអវត្តមានប្រធាន និងអនុប្រធានទាំងអស់ ហើយពុំមានលទ្ធភាពក្នុងការផ្ទេរសិទ្ធបាន អ្នកទទួលសិទ្ធិជាប្រធានស្តីទីគណបក្ស ដោយស្វ័យប្រវត្តិ ត្រូវអនុវត្តតាមឋានានុក្រម ដូចខាងក្រោម៖

១. ប្រធានគណៈកម្មាធិការនាយក

២. ប្រធានគណៈកម្មាធិការវិន័យ

៣. អនុប្រធានគណៈកម្មាធិការនាយក

៤. អនុប្រធានគណៈកម្មាធិការវិន័យ

៥. អគ្គលេខាធិការ

**ប្រការ ៤២ ៖**

ករណីប្រធានគណបក្ស ទទួលមរណភាព លាឈប់ បាត់បង់សមាជិកភាព ឬបាត់បង់សមត្ថភាព ដឹកនាំគណបក្ស ដែលបញ្ជាក់ដោយគណៈកម្មាធិការនាយក បើ ៖

- អាណត្តិនៅតិចជាង១៨ខែ អនុប្រធានគណបក្សមួយរូប ដែលមានអាយុច្រើនជាងគេ ត្រូវទទួលនាទីជាប្រធានគណបក្ស ហើយបើគ្មានអនុប្រធានគណបក្ស គណៈកម្មាធិការនាយក ត្រូវជ្រើសរើសអនុប្រធានគណបក្សថ្មីយ៉ាងតិចមួយរូប ក្នុងរយៈពេល៣ខែយ៉ាងយូរ ពីក្នុងចំណោមសមាជិករបស់ខ្លួន ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ដើម្បីជួយសម្រួលការងារប្រធានគណបក្ស រហូតដល់ចប់អាណត្តិ។
- អាណត្តិនៅលើស១៨ខែ គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវកំណត់ពេលរៀបចំធ្វើសមាជវិសាមញ្ញ ដើម្បីជ្រើសរើសប្រធានគណបក្ស និងអនុប្រធានគណបក្សថ្មី ក្នុងរយៈពេលយ៉ាងយូរ៣ខែ ដើម្បីដឹកនាំគណបក្សរហូតដល់ចប់អាណត្តិ។

ករណីថ្នាក់ដឹកនាំថ្នាក់ជាតិរបស់គណបក្ស ត្រូវបាត់បង់សមត្ថភាពដឹកនាំគណបក្សទាំងស្រុង ថ្នាក់ដឹកនាំសំខាន់ៗរបស់គណបក្សដែលនៅមានសមត្ថភាព ឬថ្នាក់ដឹកនាំថ្នាក់ក្រោមជាតិ ឬស្ថាបនិករបស់គណបក្ស ត្រូវបង្កើត គណៈកម្មាការបណ្តោះអាសន្នមួយ ដូចមានចែងក្នុងជំពូកទី៩ នៃលក្ខន្តិកៈនេះ ដើម្បីរៀបចំសម្រេចដឹកនាំគណបក្សបន្ត។

**ប្រការ ៤៣ ៖**

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវបានបញ្ចប់មុខងារ ដូចមានចែងក្នុងប្រការ១៦ និងប្រការ១៧ នៃលក្ខន្តិកៈ។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ អាចបាត់បង់សមាជិកភាពរបស់ខ្លួនដោយ ៖

- មរណភាព

- ការសុំលាលែងជាលាយលក្ខណ៍អក្សរ ដាក់ជូនប្រធានគណបក្ស
- ការបញ្ចប់សមាជិកភាពពីគណបក្ស។
- អវត្តមានក្នុងកិច្ចប្រជុំរបស់ខ្លួនចំនួន៣ដងជាបន្តបន្ទាប់ ដោយគ្មានការជូនដំណឹង ត្រូវព្រមានជាលាយលក្ខណ៍អក្សរពីប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍។ ប្រសិនបើនៅបន្តអវត្តមានក្នុងកិច្ចប្រជុំ ដោយគ្មានការជូនដំណឹងចំនួន៣ដងជាបន្តបន្ទាប់ទៀត ត្រូវបាត់បង់តួនាទីពីគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ អាចស្នើសុំឱ្យគណៈកម្មាធិការនាយក រៀបចំបំពេញបន្ថែមសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ស្របតាមប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈ។

## ផ្នែកទី៧
## រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ

**ប្រការ ៤៤ ៖**

រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ ត្រូវរៀបចំជាតំណាងបក្សភូមិ គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ និងគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត និងចលនាមហាជនតាមតម្រូវការការចាំបាច់។

**ប្រការ ៤៥ ៖**

សមាសភាពគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ រួមមាន៖

- ថ្នាក់ដឹកនាំតំណាងបក្សភូមិ(ប្រធានមួយរូប អនុប្រធានមួយរូប និងជំនួយការមួយរូប)
- ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ (ប្រធានមួយរូប អនុប្រធានយ៉ាងតិចមួយរូប លេខាមួយរូប និងប្រធានតំណាងបក្សភូមិ ក្នុងឃុំ-សង្កាត់ សាមីជាសមាជិក)
- ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ (ប្រធានមួយរូប អនុប្រធានយ៉ាងតិចមួយរូប លេខាមួយរូប និងប្រធានគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ក្នុងក្រុង-ស្រុក-ខណ្ឌ សាមីជាសមាជិក)
- ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត (ប្រធានមួយរូប អនុប្រធានយ៉ាងតិចមួយរូប លេខាមួយរូប ហេរញ្ញិកមួយរូប និងប្រធានគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ក្នុងរាជធានី-ខេត្ត សាមីជាសមាជិក)

**ប្រការ ៤៦ ៖**

តំណាងបក្សភូមិនីមួយៗ មានសមាជិកសកម្មយ៉ាងតិច៣រូប រស់នៅក្នុងភូមិសាមី ដែលស្ម័គ្រចិត្ត និងដាក់ពាក្យសុំចូលជាសមាជិកគណបក្សប្រជាធិបតេយ្យជឿនលឿន ជាសមាជិកសកម្ម។ ថ្នាក់ដឹកនាំតំណាងបក្សភូមិ តែងតាំងដោយគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត តាមសំណើរបស់គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ សម្រាប់អាណត្តិ៥ឆ្នាំ។

តំណាងបក្សភូមិនីមួយៗ មានភារកិច្ច៖

- អនុវត្ត និងផ្សព្វផ្សាយគោលនយោបាយ កម្មវិធីនយោបាយ សេចក្ដីសម្រេចនានារបស់គណបក្សទៅដល់ប្រជាពលរដ្ឋនៅក្នុងភូមិសាមី
- រាយការណ៍ជូនថ្នាក់ដឹកនាំគណបក្សអំពីសភាពការណ៍សង្គម សេដ្ឋកិច្ច នយោបាយ និងសំណូមពររបស់ពលរដ្ឋដែលកើតមានឡើងក្នុងភូមិសាមី

**ប្រការ ៤៧ ៖**

ថ្នាក់ដឹកនាំតំណាងបក្សភូមិនីមួយៗ និងប្រធានចលនាមហាជនឃុំ-សង្កាត់ (យុវជន ស្ត្រី...) មានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់សាមី។

ថ្នាក់ដឹកនាំតំណាងបក្សភូមិនីមួយ ដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ត្រូវលាលែង ពីថ្នាក់ដឹកនាំតំណាងបក្សភូមិ។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវតែងតាំងឡើងវិញនូវថ្នាក់ដឹកនាំតំណាងបក្សភូមិសាមី។

**ប្រការ ៤៨ ៖**

គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ មានចំនួនយ៉ាងច្រើនស្មើនឹងអាសនៈក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលកំណត់ដោយរាជរដ្ឋាភិបាល បូកនឹងចំនួនភូមិក្នុងឃុំ-សង្កាត់សាមី។

គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់នីមួយៗ ជ្រើសតាំងតាមរយៈការបោះឆ្នោតដោយសម្ងាត់ និងសំឡេងប្រៀបសម្រាប់អាណត្តិ៥ឆ្នាំ ជ្រើសរើសចេញពីបេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនបន្តបន្ទាប់ និងតែងតាំងដោយអគ្គលេខាធិការគណបក្ស តាមសំណើរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត។

**ប្រការ ៤៩ ៖**

គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ មានតួនាទី និងភារកិច្ច ៖

- ធានាដំណើរការគណបក្សនៅក្នុងឃុំ-សង្កាត់សាមី
- អនុវត្ត ចាត់ចែង និងផ្សព្វផ្សាយគោលនយោបាយ កម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្សដល់ប្រជាពលរដ្ឋនៅក្នុងឃុំ-សង្កាត់សាមី
- រាយការណ៍ជូនថ្នាក់ដឹកនាំគណបក្សអំពីសភាពការណ៍សង្គម សេដ្ឋកិច្ច នយោបាយ និងសំណូមពររបស់ពលរដ្ឋដែលកើតមានឡើងក្នុងឃុំ-សង្កាត់សាមី ជូនគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ។

**ប្រការ ៥០ ៖**

ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ប្រធានចលនាមហាជនឃុំ-សង្កាត់ (យុវជន ស្ត្រី...) មានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ។ ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ត្រូវលាលែងពីថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់។ ក្នុងករណីនេះ អគ្គលេខាធិការគណបក្ស ត្រូវតែងតាំងឡើងវិញនូវថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ តាមសំឡេងគាំទ្រជាបន្តបន្ទាប់នៃលទ្ធផលបោះឆ្នោតជ្រើសរើសចុងក្រោយ។

ប្រធានតំណាងបក្សភូមិ និងប្រធានចលនាមហាជនឃុំ-សង្កាត់(យុវជន ស្ត្រី...) ជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ឃុំ-សង្កាត់ ដោយស្វ័យប្រវត្តិ។

**ប្រការ ៥១ ៖**

គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ មានចំនួនយ៉ាងច្រើនស្មើនឹងអាសនៈក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ ដែលកំណត់ដោយរាជរដ្ឋាភិបាល បូកនឹងចំនួនឃុំ-សង្កាត់ ក្នុងក្រុង-ស្រុក-ខណ្ឌសាមី។

គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌនីមួយៗ ជ្រើសតាំងតាមរយៈការបោះឆ្នោតដោយសម្ងាត់ និងដោយសំឡេងប្រៀប សម្រាប់អាណត្តិ៥ឆ្នាំ ជ្រើសរើសចេញពីបេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនបន្តបន្ទាប់ និងតែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្ស តាមសំណើរបស់អគ្គលេខាធិការគណបក្ស។

**ប្រការ ៥២ ៖**

ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌនីមួយៗ ដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវលាលែងពីថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ។ ក្នុងករណីនេះប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្ស ត្រូវតែងតាំងឡើងវិញនូវថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ តាមសំឡេងគាំទ្រជាបន្តបន្ទាប់នៃលទ្ធផលបោះឆ្នោតជ្រើសរើសចុងក្រោយ។

ប្រធានគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ និងប្រធានចលនាមហាជនក្រុង-ស្រុក-ខណ្ឌ(យុវជន ស្ត្រី..) ជាសមាជិកគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌសាមី ដោយស្វ័យប្រវត្តិ។

**ប្រការ ៥៣ ៖**

គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ មានតួនាទី និងភារកិច្ច ៖

- ជានាដំណើរការគណបក្សនៅក្នុងក្រុង-ស្រុក-ខណ្ឌសាមី
- អនុវត្ត ចាត់ចែង និងផ្សព្វផ្សាយគោលនយោបាយ កម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ដល់ប្រជាពលរដ្ឋនៅក្នុងក្រុង-ស្រុក-ខណ្ឌសាមី
- រាយការណ៍ជូនថ្នាក់ដឹកនាំគណបក្សអំពីសភាពការណ៍សង្គម សេដ្ឋកិច្ច នយោបាយ និងសំណូមពររបស់ពលរដ្ឋដែលកើតមានឡើងក្នុងក្រុង-ស្រុក-ខណ្ឌសាមី ជូនគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត។

**ប្រការ ៥៤ ៖**

ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ប្រធានចលនាមហាជនក្រុង-ស្រុក-ខណ្ឌ (យុវជន ស្ត្រី...) មានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត។ ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវលាលែងពីថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្ស ត្រូវតែងតាំងឡើងវិញនូវថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ តាមសំឡេងគាំទ្រជាបន្តបន្ទាប់នៃលទ្ធផលបោះឆ្នោតជ្រើសរើសចុងក្រោយ។

**ប្រការ ៥៥ ៖**

គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត មានចំនួនយ៉ាងច្រើនស្មើនឹងអាសនៈក្រុមប្រឹក្សារាជធានី-ខេត្ត ដែលកំណត់ដោយរាជរដ្ឋាភិបាល បូកនឹងចំនួនក្រុង-ស្រុក-ខណ្ឌ ក្នុងរាជធានី-ខេត្តសាមី។

គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្តនីមួយៗ ជ្រើសតាំងតាមរយៈការបោះឆ្នោតដោយសម្ងាត់ និងដោយសំឡេងប្រៀប សម្រាប់អាណត្តិ៥ឆ្នាំ ជ្រើសរើសចេញពីបេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនបន្តបន្ទាប់ និងតែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្ស តាមសំណើរបស់អគ្គលេខាធិការគណបក្ស។

ប្រធានគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ និងប្រធានចលនាមហាជនរាជធានី-ខេត្ត(យុវជន ស្ត្រី..) ជាសមាជិកគណៈ កម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ដោយស្វ័យប្រវត្តិ។

**ប្រការ ៥៦ ៖**

គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត មានតួនាទី និងភារកិច្ច ៖

- ជានាដំណើរការគណបក្សនៅក្នុងរាជធានី-ខេត្តសាមី
- អនុវត្ត ចាត់ចែង និងផ្សព្វផ្សាយគោលនយោបាយ កម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ដល់ប្រជាពលរដ្ឋនៅក្នុងរាជធានី-ខេត្តសាមី
- ធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពការងាររបស់ខ្លួន និងអំពីសភាពការណ៍សង្គម សេដ្ឋកិច្ច នយោបាយ និងសំណូមពររបស់ពលរដ្ឋដែលកើតមានឡើងក្នុង រាជធានី-ខេត្ត ជូនអគ្គលេខាធិការគណបក្ស។

**ប្រការ ៥៧ ៖**

គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត ប្រជុំយ៉ាងតិចមួយខែម្តង។

កិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត ត្រូវមានកូរ៉ុម(៥០%+១) នៃសមាជិកទាំងមូល។

សេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត ត្រូវមានសំឡេងគាំទ្រភាគច្រើនដាច់ខាត(៥០%+១) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច។

**ប្រការ ៥៨ ៖**

គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត អាចស្នើសុំតែងតាំងទីប្រឹក្សារបស់ខ្លួនយ៉ាងច្រើន ១/៣ នៃអាសនៈក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត ដែលកំណត់ដោយរាជរដ្ឋាភិបាល។

ទីប្រឹក្សារបស់គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត តែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្តសាមី។

**ប្រការ ៥៩ ៖**

ក្រុមការងាររាជធានី-ខេត្ត និងក្រុមប្រឹក្សាភិបាលចលនាមហាជន(យុវជន ស្ត្រី...) ជាសេនាធិការរបស់គណៈកម្មាធិការប្រតិបត្តិ។

ក្រុមការងាររាជធានី-ខេត្ត និងក្រុមប្រឹក្សាភិបាលចលនាមហាជន(យុវជន ស្ត្រី...) តែងតាំងដោយប្រធានគណបក្ស តាមសំណើរបស់អគ្គលេខាធិការគណបក្ស។

ចលនាមហាជនរាជធានី-ខេត្ត(យុវជន ស្ត្រី...) តែងតាំងដោយអគ្គលេខាធិការគណបក្ស តាមសំណើរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត និងក្រុមប្រឹក្សាភិបាលយុវជន។

**ប្រការ ៦០ ៖**

នីតិវិធី និងបែបបទ រៀបចំការបោះឆ្នោតជ្រើសតាំងបេក្ខជនសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ កំណត់ដោយសេចក្តីណែនាំរបស់អគ្គលេខាធិការដ្ឋានគណបក្ស។

**ប្រការ ៦១ ៖**

ក្នុងអន្តរកាលនៃអាណត្តិទីមួយ(២០២៣-២០២៨) ការរៀបចំរចនាសម្ព័ន្ធ និងបញ្ជីបេក្ខជន យោងតាមការសម្របសម្រួលរបស់គណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ និងគណៈកម្មាធិការប្រតិបត្តិ។

## ជំពូកទី៣

## ធនធាន និងថវិការបស់គណបក្ស

**ប្រការ ៦២ ៖**

ធនធាន និងថវិការបស់គណបក្ស បានមកពីភាគទានរបស់សមាជិក និងពីវិភាគទានស្របច្បាប់របស់សប្បុរសជននានា។ ការបង់ភាគទានរបស់សមាជិក(យ៉ាងតិច) ចូលគណបក្ស ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

- សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា ត្រូវបង់ចំនួន ១២% នៃប្រាក់បំណាច់ប្រចាំខែ
- សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ត្រូវបង់ចំនួន ១០%នៃប្រាក់បំណាច់ប្រចាំខែ
- សមាជិកក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ ត្រូវបង់ចំនួន ១០%នៃប្រាក់បំណាច់ប្រចាំខែ
- សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបង់ចំនួន ១០%នៃប្រាក់បំណាច់ប្រចាំខែ
- ប្រធាន និងអនុប្រធាន នៃគណៈកម្មាធិការទាំងបី ត្រូវបង់ចំនួន ២០ម៉ឺនរៀល ប្រចាំខែ
- សមាជិកគណៈកម្មាធិការទាំងបី ត្រូវបង់ចំនួន ១ម៉ឺនរៀល ប្រចាំខែ
- សមាជិកក្រុមការងាររាជធានី-ខេត្ត ត្រូវបង់ចំនួន ១ម៉ឺនរៀល ប្រចាំខែ

គណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ ដែលមិនស្ថិតនៅក្នុងតំណែងជាសមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ អាចបង់ភាគទានប្រចាំខែតាមការស្ម័គ្រចិត្ត។

សមាជិកដែលជាប់កាតព្វកិច្ចបង់ភាគទានប្រចាំខែលើសពីមួយ ត្រូវបង់ភាគទានមួយដែលខ្ពស់ជាងគេ។

**ប្រការ ៦៣ ៖**

ភាគទានប្រចាំខែរបស់សមាជិកព្រឹទ្ធសភា រដ្ឋសភា និងគណៈកម្មាធិការទាំងបី រួមទាំងវិភាគទានស្របច្បាប់របស់សប្បុរសជននានា ត្រូវបង់ចូលទីស្នាក់ការកណ្តាលរបស់គណបក្ស។

ភាគទានប្រចាំខែរបស់ក្រុមការងាររាជធានី-ខេត្ត សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ រួមទាំងវិភាគទានស្របច្បាប់របស់សប្បុរសជននានាក្នុងរាជធានី-ខេត្ត ត្រូវរក្សាទុកសម្រាប់ដំណើរការការងារគណបក្សក្នុងរាជធានី-ខេត្តសាមី។

**ប្រការ ៦៤ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស អាចកំណត់ការបង់ភាគទានបន្ថយ ឬបន្ថែម ដល់ថ្នាក់ដឹកនាំគណបក្សដែលជាប់កាតព្វកិច្ចទាំងអស់ក្នុងករណីចាំបាច់។

**ប្រការ ៦៥ ៖**

ថ្នាក់ដឹកនាំគណបក្សគ្រប់លំដាប់ថ្នាក់ ដែលមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុង ប្រការ៥៧ ខាងលើ នឹងត្រូវមានវិធានការដូចខាងក្រោម៖

**ក. ចំពោះការបង់ចូលទីស្នាក់ការកណ្តាលរបស់គណបក្ស ៖**

- បើមិនបង់ភាគទានចំនួនពីរខែបន្តបន្ទាប់ ហេរញ្ញិកត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួន ដោយតម្រូវឱ្យបង់ភាគទានទាំងពីរខែនោះ ក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីការជូនដំណឹង
- បើនៅតែមិនបង់ភាគទានពីរខែបន្តបន្ទាប់ទៀត ហេរញ្ញិកត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួនដោយតម្រូវឱ្យបង់ភាគទានទាំងបួនខែនោះ ក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីជូនដំណឹង
- បើសាមីខ្លួននៅតែមិនបង់ភាគទានជូនគណបក្ស ហេរញ្ញិក ត្រូវធ្វើរបាយការណ៍ទៅគណៈកម្មាធិការវិន័យដើម្បីដោះស្រាយ។

**ខ. ចំពោះក្រុមការងាររាជធានី-ខេត្ត ៖**

- បើមិនបង់ភាគទានចំនួនពីរខែបន្តបន្ទាប់ ប្រធានក្រុមការងារត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួន ដោយតម្រូវឱ្យបង់ភាគទានទាំងពីរខែនោះ ក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីការជូនដំណឹង
- បើនៅតែមិនបង់ភាគទានពីរខែបន្តបន្ទាប់ទៀត ប្រធានក្រុមការងារត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួន ដោយតម្រូវឱ្យបង់ភាគទានទាំងបួនខែនោះ ក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីជូនដំណឹង
- បើសាមីខ្លួននៅតែមិនបង់ភាគទានជូនគណបក្ស ប្រធានក្រុមការងារត្រូវកោះប្រជុំក្រុមការងាររាជធានី-ខេត្តដើម្បីដោះស្រាយ។

**គ. ចំពោះថ្នាក់ដឹកនាំគណបក្សថ្នាក់ក្រោមជាតិ ៖**

- បើមិនបង់ភាគទានចំនួនពីរខែបន្តបន្ទាប់ ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួន ដោយតម្រូវឱ្យបង់ភាគទានទាំងពីរខែនោះ ក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីការជូនដំណឹង
- បើនៅតែមិនបង់ភាគទានពីរខែបន្តបន្ទាប់ទៀត ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួន ដោយតម្រូវឱ្យបង់ភាគទានទាំងបួនខែនោះ ក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីជូនដំណឹង
- បើសាមីខ្លួននៅតែមិនបង់ភាគទានជូនគណបក្ស ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវកោះប្រជុំគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ដើម្បីដោះស្រាយ។

គណៈកម្មាធិការវិន័យ ដោយសហការជាមួយអគ្គលេខាធិការដ្ឋាន និងហេរញ្ញិក មានភារកិច្ចរៀបចំបែបបទ និងនីតិវិធីសម្រាប់ការដាក់វិន័យចំពោះសមាជិក ដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងប្រការ៥៧ នៃបទបញ្ញាផ្ទៃក្នុងគណបក្ស។

## ជំពូកទី៤
## ក្រមសីលធម៌ វិន័យ ពិន័យ

**ប្រការ ៦៦ ៖**

គោលបំណងក្នុងការកំណត់នូវក្រមសីលធម៌-វិន័យនេះឡើង គឺដើម្បីឱ្យគណបក្សមានគោលការណ៍ច្បាស់លាស់ និងអនុវត្តតាមស្មារតី នៃការកំណត់របស់សមាជិកទាំងអស់ ដែលត្រូវមាន «**សីលធម៌ វិន័យ និងការទទួលខុសត្រូវ**»។ សមាជិកគណបក្សត្រូវគោរពគោលការណ៍នយោបាយ ដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវ សីលធម៌ គុណធម៌ សច្ចធម៌ វិន័យ សុចរិតភាព ថ្លៃថ្នូរ និងវិជ្ជាជីវៈ ក្នុងការបម្រើប្រជាពលរដ្ឋ ជាតិមាតុភូមិ ដើម្បីទទួលបានការគាំទ្រពីប្រជាពលរដ្ឋក្នុងការកសាងប្រជាធិបតេយ្យជឿនលឿន និងទុកជាគំរូដ៏ល្អសម្រាប់អ្នកបន្តវេន។

**ប្រការ ៦៧ ៖**

គោលការណ៍សីលធម៌សំខាន់ ដែលសមាជិកគ្រប់រូប ត្រូវគោរពអនុវត្តដូចតទៅ៖

១. សុចរិតភាព ៖
- បំពេញការងារដោយភាពស្មោះត្រង់
- មិនទទួលសំណូក ឬអត្ថប្រយោជន៍បុគ្គល
- មិនប្រើឥទ្ធិពលគណបក្សសម្រាប់ផលប្រយោជន៍ជាបុគ្គល/គ្រួសារ

២. ការគោរពច្បាប់ ៖
- រដ្ឋធម្មនុញ្ញ ច្បាប់ជាតិ និងបទប្បញ្ញត្តិនានា
- ធ្វើខ្លួនជាគំរូល្អនៅក្នុងក្រុមដឹកនាំ ក្នុងសហគមន៍

៣. ការទទួលខុសត្រូវ ៖
- នូវសកម្មភាពរបស់ខ្លួន
- នូវការបញ្ចេញមតិ យោបល់ ឬព័ត៌មានជាសាធារណៈ
- នូវការជូនដំណឹងដល់សមាជិក និងប្រជាពលរដ្ឋពាក់ព័ន្ធ

៤. ការសរសេរ ឬសម្តី ៖
- មិនធ្វើព័ត៌មានក្លែងក្លាយ លាបពណ៌ មួលបង្កាច់ ញុះញង់ នាំឱ្យសង្គមជាតិបែកបាក់
- មិនប្រើប្រាស់ភាសាអសុរោះ ជេរប្រមាថ បង្ខូចកេរ្តិ៍
- គោរពមតិផ្ទុយ ឬមតិផ្សេងគ្នា ដោយគោរពផ្តល់តម្លៃគ្នាទៅវិញទៅមក ប្រកបដោយភាពថ្លៃថ្នូរ

៥. គោរពសិទ្ធិមនុស្ស ៖
- មិនប្រើអំពើហិង្សាគ្រប់រូបភាព
- គាំទ្រសិទ្ធិសមភាពយេនឌ័រ ជនងាយរងគ្រោះ ជនមានពិការភាព និងកុមារ
- ជំរុញលើកទឹកចិត្តការចូលរួមរបស់យុវជន និងស្ត្រី ក្នុងកិច្ចការសង្គម សេដ្ឋកិច្ច និងនយោបាយ។

**ប្រការ ៦៨ ៖**

សមាជិកគណបក្សគ្រប់លំដាប់ថ្នាក់ត្រូវគោរពវិន័យ និងធ្វើសកម្មភាពនយោបាយដោយត្រូវ៖

១. គោរពវិន័យគណបក្ស ៖

- គោរពសេចក្តីសម្រេចរបស់គណបក្ស
- មិនធ្វើសកម្មភាពផ្ទុយពីគោលនយោបាយ ឬគោលការណ៍របស់គណបក្ស
- ជៀសវាងសកម្មភាពដែលបង្កការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះគណបក្ស

២. ការបង្ហាញតម្លាភាព ៖
- បង្ហាញប្រភពថវិកា និងការចំណាយនូវការងាររបស់ខ្លួនទាក់ទងនឹងគណបក្ស
- មិនប្រើប្រាស់ធនធានគណបក្សដោយខុសគោលដៅកំណត់

៣. វិន័យក្នុងការផ្សព្វផ្សាយ
- មិនត្រូវផ្សព្វផ្សាយ ឬបន្តព័ត៌មានក្លែងក្លាយ ឬគ្មានប្រភពច្បាស់លាស់
- មិនបង្កើតព័ត៌មានក្លែងក្លាយ
- មិនប្រើរូបភាពក្នុងគោលបំណងបោកបញ្ឆោតប្រជាពលរដ្ឋ

**ប្រការ ៦៩ ៖**

ថ្នាក់ដឹកនាំថ្នាក់ជាតិ និងតំណាងគណបក្ស ដែលមានសេចក្តីសម្រេចតែងតាំងជាផ្លូវការពីគណបក្ស ត្រូវប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ តម្លាភាព វិន័យ និង

១. ធ្វើជាគំរូល្អដោយត្រូវ ៖
- គោរពតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស និងរាល់លិខិតច្បាប់ បទប្បញ្ញត្តិជាធរមាន
- សម្រេចចិត្តដោយតម្កល់ឧត្តមប្រយោជន៍ជាតិខ្មែរជាធំ ជាពិសេសបូរណភាពទឹកដី និងអធិបតេយ្យជាតិ

២. ប្រើអំណាច ឬឥទ្ធិពល នាំឱ្យប៉ះពាល់ផលប្រយោជន៍គណបក្ស ៖
- មិនបង្កើតបក្ខពួក ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន
- មិនចូលរួម ឬប្រព្រឹត្តិអំពើពុករលួយ
- មិនប្រើតំណែងតួនាទីសម្រាប់ទទួលអត្ថប្រយោជន៍ផ្ទាល់ខ្លួន/ក្រុមគ្រួសារ

៣. ការទទួលខុសត្រូវជាសាធារណៈ ៖
- ឆ្លើយតបទៅនឹងប្រជាពលរដ្ឋដោយភាពសមរម្យថ្លៃថ្នូរ
- បង្ហាញសកម្មភាពដោយសុចរិតភាព

៤. គាំទ្រ និងអនុវត្តនូវប្រជាធិបតេយ្យ
- អនុវត្ត ឬដោះស្រាយដោយសន្តិវិធី អហិង្សា
- គោរពការបោះឆ្នោត និងឆន្ទៈម្ចាស់ឆ្នោត

**ប្រការ ៧០ ៖**

សមាជិកគណបក្សត្រូវគោរព និងអនុវត្តនូវការ ៖
- ចូលរួមដោយស្មោះត្រង់
- ផ្សព្វផ្សាយគោលការណ៍ គោលនយោបាយគណបក្ស
- ទប់ស្កាត់សកម្មភាពប៉ះពាល់ដល់កេរ្តិ៍ឈ្មោះគណបក្ស
- ប្រកាន់យកនូវវប្បធម៌នៃការបញ្ចេញមតិ

**ប្រការ ៧១ ៖**

សមាជិកគណបក្សទាំងអស់ត្រូវ**ហាមមិនឱ្យ** ៖
- ទទួល ឬផ្តល់សំណូក ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន

- ប្រើថវិកាគណបក្សសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ឬខុសពីប្រយោជន៍គណបក្ស
- ផ្សព្វផ្សាយ ឬផ្សាយបន្តព័ត៌មានក្លែងក្លាយ ឬគ្មានប្រភពច្បាស់លាស់
- ធ្វើសកម្មភាពបង្កហិង្សា ឬប្រើអំពើហិង្សា
- ប្រើឥទ្ធិពល ឬដាក់សម្ពាធលើអ្នកគាំទ្រ ឬសមាជិកណាម្នាក់

**ប្រការ ៧២ ៖**

ក្នុងករណីមានសមាជិកណាប្រព្រឹត្តខុសទៅនឹងវិន័យ ឬល្មើសក្រមសីលធម៌ ដូចដែលមានចែងក្នុងបទបញ្ញាផ្ទៃក្នុងគណបក្សនេះ ត្រូវអនុវត្តវិធានការដូចតទៅ ៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ដក ឬព្យួរសិទ្ធិសមាជិកបណ្តោះអាសន្ន (សិទ្ធិនៃការសម្រេចចិត្ត)
- ដកហូតតំណែងក្នុងគណបក្ស (រក្សាជាសមាជិក)
- លុបឈ្មោះចេញពីគណបក្ស (ករណីធ្ងន់ធ្ងរ)

គណៈកម្មការវិន័យទទួលបន្ទុកពិនិត្យ និងសម្រេចតាមនិតិវិធីនៃការដាក់ពិន័យនេះ ដូចមានចែងក្នុងប្រការ១នៃបទបញ្ញាផ្ទៃក្នុងនេះ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ ៧៣ ៖**

ក្នុងអំឡុងអន្តរកាល ការដឹកនាំត្រូវស្របនឹងខ្លឹមសារដែលមានចែងក្នុងអន្តរប្បញ្ញត្តិ នៃលក្ខន្តិកៈ។

**ប្រការ ៧៤ ៖**

ការធ្វើវិសោធនកម្មបទបញ្ញាផ្ទៃក្នុងរបស់គណបក្ស ជាសមត្ថកិច្ចរបស់គណៈកម្មាធិការនាយក តាមសំណើរបស់ប្រធានគណបក្ស ឬប្រធានគណៈកម្មាធិការនាយក ឬ១/៣ នៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ១/៣ នៃសមាជិកគណៈកម្មាធិការនាយក។

**ប្រការ ៧៥ ៖**

បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានារបស់គណបក្សត្រូវស្របនឹងលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងរបស់គណបក្ស។

**ប្រការ ៧៦ ៖**

បទបញ្ញាផ្ទៃក្នុងនេះត្រូវបានអនុម័តដោយគណៈកម្មាធិការនាយក ក្នុងកិច្ចប្រជុំនាថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៥

**ប្រការ ៧៧ ៖**

បទបញ្ញាផ្ទៃក្នុងនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណបក្ស។

ថ្ងៃ អាទិត្យ ១២កើត ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៥

**ប្រធានគណបក្ស**

**យ៉ែម បុញ្ញឫទ្ធិ**